# ការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

## ១- អត្ថប្រយោជន៍នៃការចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារៈ

ការចិញ្ចឹមសត្វរបស់ប្រជាកសិករនៅតាមជនបទជាផ្នែកមួយដែលចូលរួមក្នុងវិស័យកសិកម្ម ជាពិសេស ចូលរួមក្នុងការអភិវឌ្ឍសហគមន៍ និងធ្វើឱ្យជីវភាពប្រជាជនបានរីកចម្រើនមួយកម្រិត ដោយប្រើប្រាស់ធនធាន ដែលមានស្រាប់នៅក្នុងស្រុក។ កសិករមួយភាគធំនៅប្រទេសកម្ពុជានិយមចិញ្ចឹមជ្រូក ដោយពួកគាត់យល់ឃើញ ថាៈ ជាការសន្សំប្រាក់ និងបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ផ្តល់ជាម្ហូបអាហារ លាមករបស់វាអាចប្រើជាជីសម្រាប់ ដាក់ដំណាំផ្សេងៗ។ ជ្រូកជាសត្វដែលមានសមត្ថភាពក្នុងការផលិតសាច់ ការប្រើប្រាស់ចំណីបានល្អ ផ្តល់ទិន្នផល ដែលមានគុណភាពខ្ពស់ សម្របសម្រួលបានទៅតាមមជ្ឈដ្ឋានធម្មជាតិ និង មានសមត្ថភាពខ្ពស់ក្នុងការផលិតកូន។ មេជ្រូកអាចបង្កើតកូនបានជាមធ្យមពី ៨-១០ ក្បាល ក្នុង ១សា។

## ២- អំពីពូជជ្រូកៈ

ពូជជាកត្តាមួយក្នុងចំណោមកត្តាដទៃទៀតដែលមានឥទ្ធិពលយ៉ាងខ្លាំងវិស័យចិញ្ចឹមសត្វ។ ដូច្នេះអ្នកចិញ្ចឹម គួរយកចិត្តទុកដាក់ជ្រើសរើសពូជឱ្យបានត្រឹមត្រូវដើម្បីយកមកចិញ្ចឹម។

ក- <u>ពូជជ្រូកដែលចិញ្ចឹមនៅក្នុងប្រទេសកម្ពុជាៈ</u>

នៅប្រទេសកម្ពុជាមានពូជជ្រូកជាច្រើន ដែលពូជជ្រូកទាំងនេះមានប្រភពមកពីបរទេស និង ពូជជ្រូកក្នុង ស្រុក។ ពូជជ្រូកក្នុងស្រុកមានពូជកណ្តុរ ពូជដំរី ពូជកំពត ពូជហៃណាំ និង ពូជជ្រូកដែលនាំចូលពីបរទេសមានពូជ ឡាកវ៉ាយ ឬ យ៉កសៀរ ពូជឡែនរ៉េស ពូជដុយរ៉ុក ពូជហាំសៀ ពូជភីទ្រៀន។

១- <u>ពូជក្នុងស្រុកៈ</u>

- <u>ពូជកណ្តុរៈ</u> ជាពូជជ្រូកនៅអាស៊ីសុទ្ធសាធ។ ពូជកណ្តុរមានមាឌតូច ក្បាលស្រួចដូចកណ្តុរ ខ្លួនខ្លី តែក្រាស់ ខ្នងអែន សំបុកពោះធំស្ទើរប៉ះដី មានសម្បុរខ្មៅ ឬ ប្រផេះ។ ជ្រូកកណ្តុរជាពូជដែលចិញ្ចឹមក្រធំ ហើយ មានទម្ងន់ប្រហែល ៦០ គ.ក្រ នៅអាយុ ១២ ខែ។ ពូជជ្រូកកណ្តុរនេះផ្តល់កូនពី ១២ ទៅ ២៤ ក្បាលក្នុង ១ សា។

- <u>ពូជហៃណាំៈ</u> ពូជនេះមានប្រភពដើមមកពីប្រទេសចិន ហេតុនេះហើយបានជាគេដាក់ឈ្មោះ ឬ ហៅថាពូជចិន ឬ ពូជមួង ឬ ពូជយួណាន។ ពូជជ្រូកហៃណាំមានក្បាលវែង មុខចង្អៀត ត្រចៀកធ្លាក់ទៅមុខបន្តិច

ច្រមុះទូលាយ ខ្នងអែន មានសម្បុរស-ខ្មៅ។ ពូជជ្រូកហៃណាំមានទម្ងន់ប្រហែល ៦០ គ.ក្រ នៅអាយុ ៧-៩ខែ និង មានទម្ងន់ប្រហែល ១០០ គ.ក្រ នៅអាយុ ១២-១៥ ខែ។ ពូជជ្រូកហៃណាំ ជាប្រភេទពូជដែលមានខ្លាញ់ច្រើន ធន់នឹងជំងឺហើយរកឈ្មោលនៅអាយុ ៧ ខែ។

- ពូជកំពត: ពូជនេះមិនមានប្រភពច្បាស់លាស់ទេ។ ពូជជ្រូកកំពតមានរាងដូចជ្រូកកណ្តុរខ្នងអែន ខ្លាំង ក្រចកជើងទាំងពីរខាងក្រោយប៉ះដី ហើយមានរោមពណ៌ខ្មៅ។ ជ្រូកពូជកំពតមានទម្ងន់ប្រហែល ៦០ គ.ក្រ នៅអាយុប្រហែល ៨-៩ ខែ និង អាយុពី ១៣-១៦ ខែ មានទម្ងន់ ១០០ គ.ក្រ។





២-ពូជនាំចូលពីបរទេស:

- យ៉កស្សៀ ឬ ឡាកវ៉ាយ: ពូជនេះមានមាឌធំ ខ្លួនវែងធំស្មើពីស្មាដល់គូទ ស្រឡះល្អ ដំណើររវៀស វៃ មានរោមទន់ពណ៌ស ត្រចៀកធំត្រង់ឈរ ហើយរាងធ្លាក់ទេខុបន្តិច ក្បាលធំ ថ្ពាសទូលាយ មាត់រាងខើចទៅលើ ភ្នែកវៃ មុខកោង ខ្នងត្រង់ទូលាយ ពោះសម ទ្រូងជ្រៅទូលាយ ភ្លៅធំវែង ជើងវែងហើយមាំ។ ពូជជ្រូកនេះពូកែ ចិញ្ចឹមកូន សាយកូន មានទឹកដោះច្រើន ហើយកូនជាមធ្យមក្នុងមួយសម្បុកប្រហែលពី ១០-១១ ក្បាល។





- ឡែនរ៉េស: ជាប្រភេទពូជជ្រូកដែលផ្តល់សាច់ក្រហមច្រើន។ ជ្រូកប្រភេទនេះមានរោមពណ៌ស ខ្លួនវែង ក្បាលតូច មាត់តូចវែងត្រង់ ថ្ពាសតូច ស្លឹកត្រចៀកធំធ្លាក់ទៅមុខគ្របភ្នែកទាំងពីរ ខ្លួនវែងត្រង់ ជើងទាំង បួនតូចតែអាចរក្សាជំហរបានល្អ។ កូនច្រើនពី ១០-១១ ក្បាលក្នុង១សម្បុក។ កូនជ្រូកដែលកើតមកមានទំហំស្មើៗ គ្នា។




- <u>ឌុយរ៉ុក:</u> មានមាឌមាំ រហ័សរហួន មានពណ៌ក្រហមព្រលែត ជើងវែង ភ្លៅចង្អៀត ធន់នឹងជំងឺ អត្រាសាច់ក្រហមច្រើន តែមានកូនតិចក្នុងមួយសម្បុកប្រហែលពី ៩-១០ ក្បាល។ គេច្រើនយកពូជនេះទៅបង្កាត់ជាមួយពូជដទៃទៀតដើម្បីទទួលបានសាច់ក្រហមច្រើនហើយកូនចិញ្ចឹមឆាប់ធំ។

  

- <u>ហាំស្សៀ:</u> មានមាឌល្មម រហ័សរហួន សម្បូរសាច់ក្រហមច្រើន មានមុខត្រង់វែង ត្រចៀកឈរ ជាពូជជ្រូកដែលសាយកូន និង ពូកែចិញ្ចឹមកូន ជាពិសេសពូជជ្រូកនេះមានលក្ខណៈសម្គាល់ មានរង្វង់ពណ៌សពទ្ធ័ ជុំវិញស្មា និងជើងមុខ។

  

- <u>ប៉ែកស្សៀ:</u> ជាប្រភេទជ្រូកដែលមានពណ៌ខ្មៅ មានមាត់រាងង ហើយមុខរាងកោង ត្រចៀកឈរងាកទៅមុខបន្តិច។ ជ្រូកនេះមានលក្ខណៈពិសេសពណ៌ស ៦ ចំណុចគឺនៅជើងទាំងបួន កន្ទុយ និង ថ្ងាស។

ខ-<u>ការជ្រើសពូជ:</u> ការជ្រើសរើសពូជជាកត្តាសំខាន់មួយដែលយើងត្រូវតែគិតដល់តម្រូវការនៅទីផ្សារប្រភពធន់ធានដែលមាន និងលក្ខខណ្ឌអាកាសធាតុនៅក្នុងតំបន់។ ដូចនេះដើម្បីជ្រើសរើសជ្រូកយកមកចិញ្ចឹមបានល្អត្រូវយកចិត្តទុកដាក់លើ:

- របៀបជ្រើសរើសរូបរាងខាងក្រៅ:
    - ស្មាទូលាយ កវែងបន្តិច ដងខ្លួនវែង
    - ជើងមាំ និង ត្រគៀករាងសាយ

- ការជ្រើសរើសទុកធ្វើបា: ដងខ្លួនធំវែង ត្រគៀកធំទូលាយរាងទាប និង មានស្បែករលោងស្មើល្អ ខ្នងកោងដូចធ្នូ ទំហំទ្រូងធំទូលាយ ជើងធំមាំ មានដោះយ៉ាងតិចចំនួន ៦គូរ នៅជា២ជួរត្រង់ មានពងស្វាសទាំងគូធំ និង មានទំហំស្មើគ្នា។ ប្រភេទជ្រូកបាដែលចាត់ទុកថាល្អគឺ អាយុចាប់ពីអាយុពី ៧-៨ខែ សុខភាពល្អ។

- ការជ្រើសរើសជ្រូកទុកធ្វើមេ: ខ្នងមាំរាងកោងបន្តិច ដងខ្លួនវែងធំស្មើ ស្មាទូលាយសមនឹងដងខ្លួន ត្រគាកធំទូលាយ ទំហំទ្រូងធំទូលាយ ជើងនិងភ្លៅធំមាំត្រង់និងខ្ពស់ មានដោះចំនួន ៦គូរ ចន្លោះស្មើគ្នា

និងដោះនីមួយៗមិនខ្វាក់។ ជ្រូកមេដែលចាត់ទុកថាល្អគឺអាយុ ៨ខែ មានដោះយ៉ាងតិច ៦គូរមានសុខភាពល្អ។

- របៀបជ្រើសរើសតាមខ្សែលោហិតៈ ជាប្រភេទនៃការជ្រើសរើសទៅតាមពូជដែលបានបង្កាត់ប៉ុន្មានឈាម(ជ្រូកដែលគេជ្រើសរើសយកមកចិញ្ចឹមជាជ្រូកសាច់ជាទូទៅគេជ្រើសរើសយកជ្រូកដែលបានមកពីការបង្កាត់ ៣ពូជ)

- របៀបជ្រើសរើសតាមខ្សែស្រឡាយៈ ការជ្រើសរើសតាមខ្សែស្រឡាយដោយសង្កេតមើលលក្ខណៈដែលមានដូចខាងក្រោមៈ

  - ភាពសាយកូនដែលនៅពេលផ្តាច់ដោះសល់កូនលើសពី ៨ក្បាលឡើងទៅ។
  - មេជ្រូកសម្បូរទឹកដោះគ្រប់គ្រាន់
  - ក្រោយពេលផ្តាច់ដោះ កូនជ្រូកមានទម្ងន់ជាមធ្យម ១០-១៥ គ.ក្រ ក្នុង១ក្បាល
  - ចំពោះជ្រូកមេមិនធ្លាប់មានប្រវត្តិកើតជម្ងឺរលាកដោះ រលាកស្បូន និងរលូតកូន
  - មេជ្រូកចេះថែទាំកូនបានល្អ

**៣- សំណង់ទ្រុងៈ**

ទ្រុងជ្រូកជាជម្រកមួយដ៏សំខាន់ក្នុងការចិញ្ចឹមសត្វ។ ការសាងសងទ្រុងឱ្យបានត្រឹមត្រូវគឺជួយឱ្យសត្វមានសុខភាពល្អមានការលូតលាស់លឿន និងជួយកាត់បន្ថយអត្រាស្លាប់របស់ជ្រូក កាត់បន្ថយជំងឺដែលកើតឡើងដោយថៃដន្យ។ ដូចនេះមុននិងសាងសងទ្រុងជ្រូកយើងត្រូវគិតដល់កត្តាមួយចំនួនដូចជាៈ ការជ្រើសរើសទីតាំងសង់ ទ្រុងនៅជិតប្រភពទឹក សំណង់ទ្រុងត្រូវនៅឆ្ងាយពីទីប្រជុំជន កម្រាលទ្រុង ដំបូលទ្រុង ។ល។

- ការជ្រើសរើសទីតាំងសង់ទ្រុងៈ ទីតាំងដែលត្រូវសង់ទ្រុងគឺត្រូវជ្រើសរើសកន្លែងដែលមិនលិចទឹក ដីមានសភាពខ្ពស់ស្ងួត ងាយស្រួលក្នុងការបង្ហូរបញ្ចេញកាកសំណល់ សំណងទ្រុងត្រូវមានទីធ្លាធំល្មមដើម្បីងាយស្រួលឱ្យសត្វរត់លេង ឬធ្វើចលនា មានពន្លឺថ្ងៃចេញចូលគ្រប់គ្រាន់ដើម្បីឱ្យជ្រូករីកលូតលាស់បានល្អ មានខ្យល់អាកាសល្អ។ ក្រៅពីនេះត្រូវមានទីវាលសម្រាប់ដាំដំណាំ ឬបន្លែបៃតងសម្រាប់ជាចំណីបន្ថែមឱ្យសត្វស៊ី។

- ដំបូលទ្រុងៈ ចំពោះដំបូលទ្រុង គេនិយមប្រកស្បូវ ឬស្លឹកត្នោត។

- កម្រាលទ្រុងៈ ចំពោះកម្រាលទ្រុងជ្រូកត្រូវមានភាពរឹងមាំល្អ មិនដក់ទឹក និងជ្រូកមិនអាចឈ្មុសឱ្យរបើកបាន ត្រូវសង់ឱ្យមានជម្រាលបន្តិចដើម្បីងាយស្រួលក្នុងការលាងសម្អាតទ្រុង។ កម្រិតទេគឺចាប់ពី ២-៤ដឺក្រេ។ ម៉្យាងវិញទៀតកម្រាលបាតទ្រុងមិនត្រូវឱ្យរលោងព្រោះវាងាយស្រួលធ្វើឱ្យគ្រោះថ្នាក់រអិលដួលដែលបណ្តាលឱ្យថ្លោះ ឬបាក់ជើង។

- គួរសង់ទ្រុងជ្រូកឱ្យស្ថិតនៅក្នុងជួរទិសខាងលិច និង ខាងកើត (បណ្ដោយថ្ងៃ)

- សំណង់ទ្រុងត្រូវនៅឆ្ងាយពីទីប្រជុំជន ពីផ្ទះ ផ្លូវថ្នល់ ដែលមានមនុស្សចេញចូល និងឱ្យឆ្ងាយពីកសិដ្ឋានផ្សេងៗ។

- គួរតែមានប្រព័ន្ធបង្ហូរលាមកសត្វ

- <u>ទំហំទ្រុង:</u> គឺអាស្រ័យទៅលើចំនួនជ្រូកដែលកសិករត្រូវចិញ្ចឹម

  - ចំពោះជ្រូកទម្ងន់ ២០-៥០ គ.ក្រ: ត្រូវការសង់ទ្រុងទំហំ ១ម² ក្នុង ១ក្បាល
  - ចំពោះជ្រូកទម្ងន់ ៥០-១០០គ.ក្រ: ត្រូវការសង់ទ្រុងទំហំ ២ម² ក្នុង ១ក្បាល
  - ចំពោះមេជ្រូក: ត្រូវការសង់ទ្រុងទំហំ ២,៥ម² ក្នុង ១ក្បាល
  - ចំពោះមេជ្រូកបំបៅកូន: ត្រូវការសង់ទ្រុងទំហំ ១០ម² ក្នុង ១ក្បាល
  - ចំពោះជ្រូកបា: ត្រូវការសង់ទ្រុងទំហំ ៩ម² ក្នុង ១ក្បាល
  - ចំពោះទ្រុងសម្រាប់ចិញ្ចឹមជ្រូក ២-៣ ក្បាល: បណ្ដោយ ៣ម ទទឹង ២ម កម្ពស់ខាងទាប ២ម និង កម្ពស់ខាងខ្ពស់ ២,៥ម។

**៤- ចំណី និងការផ្ដល់ចំណីជ្រូក:**

ដើម្បីទ្រទ្រង់ការលូតលាស់របស់ជ្រូកៗត្រូវការចំណីអាហារដែលមានគុណភាព មានន័យថាចំណីអាហារណាដែលសម្បូរទៅដោយជាតិសាច់ ថាមពល សារធាតុរ៉ែ ទឹក និងសារធាតុផ្សេងៗទៀតដែលចាំបាច់សម្រាប់ការលូតលាស់របស់វា។ តម្រូវការរបស់ជ្រូកមិនដូចគ្នាទេគឺប្រែប្រួលទៅតាមដំណាក់កាលនៃការលូតលាស់។

ក-<u>ចំណីផ្ដល់ថាមពល:</u> ថាមពលជាតម្រូវការចាំបាច់ដើម្បីទ្រទ្រង់រាល់សកម្មភាពទាំងអស់របស់ជ្រូក រក្សាកម្ដៅក្នុងខ្លួន ការធំធាត់ និង ការផលិតកូន។ ចំណីផ្ដល់ថាមពលមានដូចជា:

- ពោត: ពោតជាប្រភពចំណីផ្ដល់កម្ដៅសំខាន់ចំពោះជ្រូក។ គេអាចប្រើប្រាស់ពោតក្នុងចំណីរហូតដល់ ៨៥%នៅក្នុងចំណីរបស់វា។ ចំពោះមេជ្រូកធើមគេអាចប្រើពោតនៅក្នុងចំណីក្នុងកម្រិតមួយទាប។ ពោតត្រូវកិនបំបែកមុនឱ្យទៅជ្រូកស៊ី។

- ចុងអង្ករ: គេអាចផ្ដល់ចុងអង្ករឱ្យជ្រូកស៊ីក្នុងកម្រិត ៦០%នៃចំណីរបស់វា។

- កន្ទក់: ជាប្រភេទចំណីដែលមានជាតិសរសៃ និងប្រេងច្រើន។ ចំពោះកូនជ្រូកអាចលាយកន្ទក់ត្រឹមតែ ៣០%។ ប៉ុន្តែជ្រូកសាច់អាចលាយបានរហូតដល់ ៥០% នៃចំណីរបស់វា។

- កាកស្រា: ជាប្រភពចំណីផ្ដល់កម្ដៅ ហើយជាចំណូលដែលគេមិនអាចរក្សាទុកបានយូទេ។ កាកស្រាអាចលាយក្នុងចំណីបានរហូតដល់ ៣០%។

- កាកសំណល់ផ្ទះបាយៈ មុនផ្តល់ចំណីកាកសំណល់ផ្ទះបាយឱ្យជ្រូកស៊ីត្រូវចម្អិនឱ្យបានឆ្អិនជាមុនសិន។ ចំណីផ្តល់ថាមពលជាចំណីដែលផ្តល់ ដែលមិនសូវសម្បូរជាតិសាច់ សារធាតុរ៉ែ និងវីតាមីន ដូចនេះដើម្បីឱ្យចំណីកាន់តែមានគុណភាព គេត្រូវលាយជាមួយចំណីផ្សេងៗទៀតដែលមានជាតិសាច់ សារធាតុរ៉ែ និងវីតាមីន។

ខ- ចំណីផ្តល់ប្រូតេអ៊ីនៈ

ចំណីភាគច្រើនដែលកសិករប្រើប្រាស់ប្រចាំថ្ងៃមានដូចជា បាយ កន្ទក់ ពោត បាយស្រា ដើមចេក កាកសំណល់ផ្ទះបាយ ។ល។ ប៉ុន្តែចំណីទាំងនេះមិនអាចផ្គត់ផ្គង់ជាតិសាច់គ្រប់គ្រាន់សម្រាប់បម្រើសេចក្តីត្រូវការរបស់ជ្រូកទេ។ ចំណីផ្តល់ជាតិសាច់មានដូចជាៈ

- ម្សៅសណ្តែកសៀងៈ ជាចំណីដែលសម្បូរជាតិសាច់។ មុនផ្តល់សណ្តែកសៀងឱ្យសត្វស៊ីត្រូវលីង ឬស្ងោរឱ្យឆ្អិនជាមុនសិនព្រោះនៅក្នុងសណ្តែកសៀងស្រស់មានជាតិពុល។

- ត្រីៈ កម្ទេចត្រី ម្សៅត្រី ឬ ត្រីជាប្រភពផ្តល់ជាតិសាច់ ហើយគេអាចយកទៅឱ្យជ្រូកស៊ីបាន បើគេធ្វើការចម្អិនឱ្យបានឆ្អិនល្អ។

- ស្លឹកកន្ទំថេត ឬ ស្លឹកដំឡូងមីៈ ជាចំណីដែលផ្តល់ជាតិសាច់ តែមុននឹងផ្តល់ឱ្យជ្រូកស៊ីត្រូវហាលថ្ងៃឱ្យស្ងួត ឬ ស្ងោរឱ្យឆ្អិនជាមុនសិន។

- កាកដូងៈ ជាចំណីដែលមានជាតិប្រូតេអ៊ីនទាបជាងសណ្តែកសៀង តែមិនត្រូវផ្តល់កាកដូងឱ្យលើសពី ៨%ឡើង ព្រោះកាកដូងមានឥទ្ធិពលមិនល្អដល់ការរំលាយអាហាររបស់ជ្រូក។

គ- តម្រូវការវីតាមីនៈ វីតាមីនមានតួនាទីសំខាន់ដើម្បីធ្វើឱ្យជ្រូកមានសុភាពល្អ ការលូតលាស់ និង ការបន្តពូជ។ វីតាមីនដែលខ្វះជាញឹកញាប់នៅក្នុងចំណីអាហារគឺវីតាមីនអា វីតាមីនបេកំផ្លេច ។ល។ ដើម្បីបំពេញកង្វះខាតនូវវីតាមីនទាំងនេះគេអាចផ្តល់ឱ្យតាមរយៈវីតាមីនអា មាននៅក្នុងអាហារបៃតង និងលឿង ដូចជាស្មៅ ពោតក្រហម ការ៉ុត ល្ពៅ ។ល។

- វីតាមីនបេកំផ្លេច មាននៅក្នុងអាហារបៃតង

- វីតាមីនបេ ១២ មាននៅក្នុងផលិតផលត្រី

ឃ- សារធាតុខនិក និង សារធាតុរ៉ែៈ ជាសារធាតុដែលមានសារៈសំខាន់ក្នុងការទ្រទ្រង់ជីវិត និង ជាផ្នែកមួយសំខាន់របស់គ្រោងឆ្អឹង ។ ចំណីអាហារដែលគេយកមកប្រើប្រាស់រាល់ថ្ងៃតែងតែមានសារធាតុរ៉ែមួយចំនួន សារធាតុរ៉ែ និងសារធាតុខនិកច្រើនមាននៅក្នុងប្រេម៉ិច (ប្រេម៉ិច MF6 ឬ Base mix) ។ អំបិលជួយឱ្យចំណីមានរសជាតិឆ្ងាញ់។ ក្នុងចំណីមិនត្រូវមានជាតិអំបិលមិនលើសពី 0,៥ គីឡូក្រាមឡើយ។

ង- តម្រូវការទឹក: មានតួនាទីសំខាន់ក្នុងការផលិតទឹកដោះ ឱ្យមានលំនឹងសីតុណ្ហភាពក្នុងខ្លួនសត្វ នាំជាតិពុល ដើម្បីបញ្ចេញមកខាងក្រៅ ។ល។ ត្រូវផ្តល់ទឹកឱ្យសត្វឱ្យបានគ្រប់គ្រាន់ ។

- ជ្រូកទម្ងន់ពី ១០-២៥ គ.ក្រ ត្រូវការទឹកផឹកពី ៤-៥ លីត្រ ក្នុង ១ ថ្ងៃ
- ជ្រូកទម្ងន់ពី ២៥-៥០ គ.ក្រ ត្រូវការទឹកផឹកពី ៧ លីត្រ ក្នុង ១ ថ្ងៃ
- ជ្រូកទម្ងន់ពី ៥០-១០០ គ.ក្រ ត្រូវការទឹកផឹកពី ៧-១២ លីត្រ ក្នុង ១ ថ្ងៃ

ច- ការផ្សំចំណី: ចំពោះការផ្សំចំណីសម្រាប់សត្វយើងមានវិធីច្រើនយ៉ាង ហើយការផ្សំចំណីនេះគឺទៅតាម ដំណាក់កាលលូតលាស់របស់សត្វ ។ ខាងក្រោមនេះជារូបមន្តចំណីសម្រាប់ជ្រូក:

- សម្រាប់មេជ្រូក:

| | មេផើម | |
|---|---|---|
| | រូបមន្តទី ១ | រូបមន្តទី ២ |
| ត្រកួនស្រស់ | ១,៥ គ.ក្រ | ១,៥ គ.ក្រ |
| ស្លឹកដំឡូងមីស្រស់ | ០,៨ គ.ក្រ | ០,៥ គ.ក្រ |
| ស្លឹកកន្ទំថេតស្រស់ | ០,៨ គ.ក្រ | ១,៥ គ.ក្រ |
| កន្ទក់ | ១,៥ គ.ក្រ | ១,២ គ.ក្រ |
| ចុងអង្ករ | ០ | ២០០ ក្រ |
| អំបិល | ១២ ក្រ | ១២ ក្រ |
| សរុប | ៤,៦១២ គ.ក្រ | ៤,៩១២ គ.ក្រ |

នៅខែចុងក្រោយនៃមេផើម ត្រូវបន្ថយចំនីចំនួន ២០ % នៃចំណីដែលឱ្យជ្រូកស៊ី ។ នៅសប្តាហ៍ចុងក្រោយ នៃមេជ្រូកផើមត្រូវបន្ថយចំណី ៥០% នៃចំណីដែលឱ្យទៅជ្រូក ។

| | មេជ្រូកចិញ្ចឹមកូន | |
|---|---|---|
| | រូបមន្តទី ១ | រូបមន្តទី ២ |
| ត្រកួនស្រស់ | ៣ គ.ក្រ | ១,៥ គ.ក្រ |
| ស្លឹកកន្ទំថេតស្រស់ | ០,៨ គ.ក្រ | ១,៥ គ.ក្រ |
| កន្ទក់ | ២,២ គ.ក្រ | ១,៦ គ.ក្រ |
| ចុងអង្ករ | ១ គ.ក្រ | ១,៥ គ.ក្រ |

| | | |
|---|---|---|
| អំបិល | ១៨ ក្រ | ១៨ ក្រ |
| សរុប | ៧,០១៣ គ.ក្រ | ៦,១១៨ គ.ក្រ |

- សម្រាប់កូនជ្រូក:

| | | |
|---|---|---|
| មុនកូនជ្រូកផ្តាច់ដោះត្រូវផ្តល់ចំណីបន្ថែម:<br>៤០ % នៃកន្ទក់<br>៣០ % នៃចុងអង្ករ<br>៣០ % នៃត្រកួន | | ទម្ងន់តិចជាង ៣០ គ.ក្រ |
| | ត្រកួនស្រស់ | ១ គ.ក្រ |
| | ស្លឹកកន្ទឺថេតស្រស់ | ០,៦ គ.ក្រ |
| | កន្ទក់ | ០,៦ គ.ក្រ |
| | ចុងអង្ករ | ០,៥ គ.ក្រ |
| | អំបិល | ៦ ក្រ |
| | សរុប | ២,៥០៦ គ.ក្រ |

- សម្រាប់ជ្រូកសាច់:

| ទម្ងន់ជ្រូក | ៣០-៦០ គ.ក្រ | ៦០-៨០ គ.ក្រ | ៨០-១០០ គ.ក្រ | ១០០ គ.ក្រឡើងទៅ |
|---|---|---|---|---|
| ត្រកួនស្រស់ | ១ គ.ក្រ | ២ គ.ក្រ | ២ គ.ក្រ | ១ គ.ក្រ |
| ស្លឹកដំឡូងមីស្រស់ | ០,៥ គ.ក្រ | ១ គ.ក្រ | ១ គ.ក្រ | ១ គ.ក្រ |
| ស្លឹកកន្ទឺថេតស្រស់ | ០,៥ គ.ក្រ | ០,៥ គ.ក្រ | ០,៥ គ.ក្រ | ០,៥ គ.ក្រ |
| កន្ទក់ | ១,២ គ.ក្រ | ១,២ គ.ក្រ | ១,២ គ.ក្រ | ១,២ គ.ក្រ |
| ចុងអង្ករ | ០,២ គ.ក្រ | ០ | ០ | ០ |
| មើមដំឡូងមីស្ងួត | ០,២ គ.ក្រ | ០,៦៥ គ.ក្រ | ១ គ.ក្រ | ១,១ គ.ក្រ |
| អំបិល | ១២ក្រ | ១៦ក្រ | ១៧ក្រ | ១៨ក្រ |
| សរុប | ៣,៦១២ គ.ក្រ | ៥,៣៦៦ គ.ក្រ | ៥,៧១៧ គ.ក្រ | ៥,៨១៨ គ.ក្រ |

ឆ-ការកែច្នៃចំណីសម្រាប់ជាចំណីជ្រូក:

ឆ-១- ការផ្អាប់ត្រីតូចៗជាចំណីជ្រូក: ការផ្អាប់ត្រីតូចៗ ឬក្បាលត្រីជាវិធីសាម័ញ្ញដែលយើអាចអនុវត្តបាន

ក- សម្ភារៈសម្រាប់ផ្អាប់:

- ត្រីតូចៗ ឬ កាកសំណល់ត្រី (ក្បាលត្រី) ៥០ គីឡូក្រាម
- ស្ករត្នោត: ៥ គីឡូក្រាម

- កន្ទក់: ៤៥ គីឡូក្រាម

- ថង់ផ្លាស់ស្ទិកទំហំ (កម្ពស់ 0,៨ ម៉ែត្រ ទទឹងមាត់ 0,៥ ម៉ែត្រ)

- ពោះវៀនកង់សម្រាប់ចងមាត់ថង់

- ចានដែកធំ

ខ- របៀបផ្អាប់:

- ត្រីផ្អាប់ជាចំណីសត្វមិនចាំបាច់វះពោះយកគ្រឿងក្នុងចេញទេ តែត្រូវលាងសម្អាតឱ្យបានល្អ រួចដាក់ហាលសំដិលឱ្យស្ងួតទឹកបន្តិច ទើបចាប់ផ្តើមប្រឡាក់ជាមួយស្ករត្នោត។ ប៉ុន្តែបើវះយកពោះយកគ្រឿងក្នុងចេញជាការល្អព្រោះធ្វើឱ្យស្ករអាចជ្រាបទៅក្នុងសាច់ត្រីបានឆាប់រហ័ស។

- ក្រោយពីច្របល់ត្រីជាមួយស្ករត្នោតរួច ទើបចាក់កន្ទក់ចូលទៅក្នុងល្បាយត្រី និងស្ករត្នោតច្របល់ឱ្យបានសព្វល្អទើបយកទៅចាក់ក្នុងថង់ប្លាស្ទិកនៅក្នុងពាង ឬ រណ្តៅ។

<u>**ចំណាំ:**</u> មិនត្រូវលាយត្រីជាមួយកន្ទក់មុនលាយជាមួយស្ករត្នោតទេ ព្រោះវាមិនអាចធ្វើឱ្យស្ករត្នោតជ្រាបចូលទៅក្នុងសាច់ត្រីបាននោះទេ។

គ- ទីកន្លែងសម្រាប់រក្សាទុកត្រីផ្អាប់: ត្រូវរក្សាត្រីផ្អាប់នៅក្នុងរណ្តៅ ឬ នៅក្នុងពាង ជៀសវៀងការបំផ្លាញដោយសារសត្វចង្រៃ។

ឃ- ការប្រើប្រាស់: ក្រោយពេលផ្អាប់រយៈពេល ១៥ ថ្ងៃ ទើបអាចយកត្រីផ្អាប់នេះលាយជាមួយចំណីដទៃទៀតដើម្បីឱ្យជ្រូកស៊ីបាន។

- ជ្រូកទម្ងន់ពី ១០-២៥ គីឡូក្រាម ត្រូវផ្តល់ត្រីផ្អាប់ជាមធ្យមចំនួន 0,៥ គីឡូក្រាម សម្រាប់ជ្រូក ១ក្បាលក្នុង ១ថ្ងៃ។

- ជ្រូកទម្ងន់លើសពី ២៥ គីឡូក្រាម ត្រូវផ្តល់ត្រីផ្អាប់ជាមធ្យមចំនួន ១-១,៥ គីឡូក្រាម សម្រាប់ជ្រូក ១ក្បាលក្នុង ១ថ្ងៃ។

ឆ-២- ការផ្អាប់ស្លឹកដំឡូងឈើ:

ក- សម្ភារៈសម្រាប់ផ្អាប់:

- ស្លឹកដំឡូងឈើស្រស់ត្រូវបេះទងស្លឹកចេញហើយកាត់ឱ្យនៅតូច(ទំហំពី ៣-៤ សង់ទីម៉ែត្រ) ១00 គីឡូក្រាម។

- ស្ករត្នោត: ៥ គីឡូក្រាម

- ថង់បាស់ស្ទិកទំហំ (កម្ពស់ 0,៨-១ ម៉ែត្រ ទទឹងមាត់ 0,៥ ម៉ែត្រ)

- ពោះវៀនកង់សម្រាប់ចងមាត់ថង់

ខ- របៀបផ្អាប់៖

- យកស្លឹកដំឡូងមីដែលបានកាត់តូចៗចំនួន ១០០ គីឡូក្រាមលាយជាមួយស្ករត្នោតចំនួន ៥ គីឡូក្រាមឱ្យបានសព្វល្អមុននឹងច្រកចូលទៅក្នុងថងប្លាស្ទិក។

- ច្រកល្បាយស្លឹកដំឡូងឈើដែលច្របល់រួចដាក់ចូលទៅក្នុងថងប្លាស្ទិក។ ដាក់ស្លឹកដំឡូងឈើជាស្រទាប់ៗ ចូលទៅក្នុងថង់ដើម្បីងាយស្រួលសង្កត់ឱ្យណែនយកខ្យល់ចេញ។

**<u>ចំណាំ:</u>** ត្រូវសង្កត់យកខ្យល់ចេញឱ្យអស់មុននឹងចងមាត់ថង់។

គ- ទីកន្លែងសម្រាប់រក្សាទុកត្រីផ្អាប់៖ ត្រូវរក្សាត្រីផ្អាប់នៅក្នុងរណ្តៅ ឬ នៅក្នុងពាង ជៀសវៀងការបំផ្លាញដោយសារសត្វចង្រៃ។

ឃ- ការប្រើប្រាស់៖ ក្រោយពេលផ្អាប់រយៈពេល ១៥ ថ្ងៃ ទើបអាចដាក់លាយជាមួយចំណីដទៃទៀត ឱ្យជ្រូកស៊ីបាន។ ស្លឹកដំឡូងឈើដែលមានគុណភាពមានក្លិនមិនជូរខ្លាំង និង រក្សាពណ៌បៃតងដដែល តែមានលឿងតិចៗ។ ក្រោយពីបើកយកផ្អកមកប្រើប្រាស់ហើយ មិនត្រូវទុកថង់ឱ្យនៅចំហរទេ។ គេអាចឱ្យស្លឹកដំឡូងឈើផ្អាប់ក្នុងកម្រិត ជាមធ្យម ពី 0,៥-៣ គីឡូក្រាម ក្នុង ១ថ្ងៃ។ ម៉្យាងវិញទៀតគេអាចលាយស្លឹកដំឡូងឈើផ្អាប់ក្នុងកម្រិតត្រឹមតែ ១0 ភាគរយ ប៉ុណ្ណោះនៅពេលដែលលាយជាមួយកន្ទក់។

ឆ-៣- ការធ្វើផ្អកមើមដំឡូងឈើ៖

ក- សម្ភារៈសម្រាប់ផ្អាប់៖

- កាប់មើមដំឡូងឈើជាដុំតូចៗ (ទំហំពី ៣-៤ សង់ទីម៉ែត្រ)៖ ១០០ គីឡូក្រាម។
- អំបិល៖ ៥ គីឡូក្រាម
- ថង់ផ្លាស់ស្ទិកទំហំ (កម្ពស់ 0,៨ម៉ែត្រ ទទឹងមាត់ 0,៥ ម៉ែត្រ)
- ពោះវៀនកង់សម្រាប់ចងមាត់ថង់

ខ- របៀបផ្អាប់៖

- យកមើមដំឡូងឈើដែលបានកាត់តូចៗចំនួន ១០០ គីឡូក្រាមលាយជាមួយអំបិលចំនួន ៥ គីឡូ ក្រាម ឱ្យបានសព្វល្អ មុននឹងច្រកចូលទៅក្នុងថងប្លាស្ទិក។

- ច្រកល្បាយមើមដំឡូងឈើដែលច្របល់រួចដាក់ចូលទៅក្នុងថងប្លាស្ទិក។ ដាក់ស្លឹកដំឡូងឈើជាស្រទាប់ ៧ ចូលទៅក្នុងថង់ដើម្បីងាយស្រួលសង្កត់ឱ្យណែនយកខ្យល់ចេញ។

- យើងត្រូវប្រើថង់ប្លាស្ទីកចំនួន ២ ជាន់ ដើម្បីជៀសវាងការធ្លុះធ្លាយធ្វើឱ្យខ្យល់ចូលខូចមើមដំឡូងផ្អាប់។

**<u>ចំណាំ:</u>** ត្រូវសង្កត់យកខ្យល់ចេញឱ្យអស់មុននឹងចងមាត់ថង់។

គ- ទីកន្លែងសម្រាប់រក្សាទុកមើមដំឡូងផ្អាប់: ត្រូវរក្សាត្រីផ្អាប់នៅក្នុងរណ្តៅ ឬ នៅក្នុងពាង ជៀសវៀងការបំផ្លាញដោយសារសត្វចង្រៃ។

ឃ- ការប្រើប្រាស់:

- ក្រោយពេលផ្អាប់រយៈពេល ១៥ ថ្ងៃ ទើបអាចដាក់លាយជាមួយចំណីដទៃទៀតឱ្យជ្រូកស៊ីបាន។ មើមដំឡូងឈើដែលមានគុណភាព មានក្លិនប្រហើរខ្លាំង ហើយមានពណ៌ប្រផេះស្រាល។

- ចំពោះជ្រូកអាយុពី ២-៤ ខែ គេអាចឱ្យមើមដំឡូងឈើ ផ្អាប់ក្នុងកម្រិតពី ១-១,៥ គីឡូក្រាម ក្នុង ១ថ្ងៃ។

- ចំពោះជ្រូកអាយុលើសពី ៤ខែ គេអាចឱ្យមើមដំឡូងឈើផ្អាប់ក្នុងកម្រិតពី ៣-៦ គីឡូក្រាម ក្នុង ១ថ្ងៃ។

- ក្រោយពីបើកយកផ្នកមកប្រើប្រាស់ហើយ មិនត្រូវទុកថង់ឱ្យនៅចំហរទេ។

**៥- សញ្ញាណនៃការរកឈ្មោល:** ការរកឈ្មោលលើកដំបូងរបស់មេជ្រូកគឺនៅអាយុ ៥,៥ ខែ។ សញ្ញាណនៃការរកឈ្មោលបានបង្ហាញដូចជា:

- មេជ្រូកមិនស៊ីចំណី
- កកេរទ្រុង រត់ឆ្វេឆ្វា នៅមិនស្ងៀម
- មេជ្រូកឡើងពាក់ជ្រូកដទៃទៀតដែលនៅជិត
- មេជ្រូកឈរនៅស្ងៀមនៅពេលដែលយើងយកដៃទៅសង្កត់ខ្នង
- ប្រដាប់បន្តពូជរីកធំ មានពណ៌ស៊ីជម្ពូ
- មានទឹករំអិលថ្លា១ហូរចេញពីប្រដាប់បន្តពូជ

**៦- ពេលវេលាដែលត្រូវបង្កាត់:**

នៅពេលដែលជ្រូកបង្ហាញការរកឈ្មោលភ្លាមយើងគួរគិតថាតើពេលណាដែលត្រូវបង្កាត់ព្រោះថាការរកឈ្មោល របស់មេជ្រូកមានរយៈពេលតែ ៣-៤ ថ្ងៃ ប៉ុណ្ណោះ។ យើងគួរតែជៀសវាងការបង្កាត់លឿនពេក ឬ យឺតពេកធ្វើឱ្យការទទួលផលកូនបានចំនួនតិច។

- ថ្ងៃទី ១ ការបង្កាត់មិនទទួលបានផលល្អទេ

- ថ្ងៃទី ២ ពេលព្រឹកគឺការបង្កាត់បានទទួលលទ្ធផលល្អ។ ប៉ុន្តែការបង្កាត់នៅពេលល្ងាចគឺទទួលលទ្ធផលល្អប្រសើរជាងនៅពេលព្រឹក ។

- ថ្ងៃទី ៣ ការបង្កាត់នៅពេលព្រឹកគឺទទួលបានលទ្ធផលល្អប្រសើរជាងការបង្កាត់នៅពេលល្ងាច ។

៧- តារាងបង្ហាញអំពីថ្ងៃបង្កាត់ និងថ្ងៃកើតកូនរបស់មេជ្រូក (១១៤ ថ្ងៃ)

| បង្កាត់/កើត | | ខែ | | ថ្ងៃ | | | | | | | | | | | | | | | | | | | | | | | | | | | | ខែ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បង្កាត់ | មករា | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | មករា |
| កើត | មេសា | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ឧសភា |
| បង្កាត់ | កុម្ភៈ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | | | | កុម្ភៈ |
| កើត | ឧសភា | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | | | | មិថុនា |
| បង្កាត់ | មិនា | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | មិនា |
| កើត | មិថុនា | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | កក្កដា |
| បង្កាត់ | មេសា | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | | មេសា |
| កើត | កក្កដា | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | | សីហា |
| បង្កាត់ | ឧសភា | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ឧសភា |
| កើត | សីហា | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | កញ្ញា |
| បង្កាត់ | មិថុនា | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | | មិថុនា |
| កើត | កញ្ញា | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | | តុលា |
| បង្កាត់ | កក្កដា | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | កក្កដា |
| កើត | តុលា | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | វិច្ឆិកា |
| បង្កាត់ | សីហា | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | សីហា |
| កើត | វិច្ឆិកា | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ធ្នូ |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បង្កាត់ | កញ្ញា | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | | កញ្ញា |
| កើត | ធ្នូ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | | មករា |
| បង្កាត់ | តុលា | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | តុលា |
| កើត | មករា | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | កុម្ភៈ |
| បង្កាត់ | វិច្ឆិកា | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | | វិច្ឆិកា |
| កើត | កុម្ភៈ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | | មិនា |
| បង្កាត់ | ធ្នូ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ធ្នូ |
| កើត | មិនា | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | មេសា |

**៨- លក្ខណៈសម្គាល់មេផើម:** ក្រោយពីការបង្កាត់រយៈពេល ២១ថ្ងៃ បើជ្រូកមិនបង្ហាញការរកឈ្មោលទេគឺមានន័យថាមេជ្រូកនេះផើម ។ លក្ខណៈសម្គាល់មេជ្រូកផើមគឺ:

- មិនបង្ហាញសញ្ញាណនៃការរកឈ្មោលបើទោះបីឃើញជ្រូកបាក់ដោយ
- មេជ្រូកដេកច្រើន ស៊ីច្រើន
- រោមមានសភាពភ្លឺរលោងពីមួយថ្ងៃទៅមួយថ្ងៃ
- ពោះរីកធំ
- កន្សោមដោះទាំងពីរជួររីកធំ
- ដំណើរធ្ងន់ៗ
- មិនចូលចិត្តនៅលាយឡំជាមួយជ្រូកដទៃទៀត

**៩- ការថែទាំមេជ្រូកផើម:**

- ត្រូវបំបែកមេជ្រូកផើមឱ្យនៅដាច់ដោយឡែកពីហ្វូងសត្វ
- ចំពោះមេជ្រូកផើមមិនត្រូវធ្វើការបម្លាស់ទីដោយការដឹកជញ្ជូនឡើយ
- ត្រូវផ្តល់បន្លែបន្ថែមដូចជា: ត្រកួន ស្លឹកដំឡូងឈើ ស្លឹកកន្ទុំផេត ផ្ទីរ។ល។
- ត្រូវផ្តល់ទឹកឱ្យបានគ្រប់គ្រាន់
- ជៀសវាងមេជ្រូកធាត់ពេក ឬ ស្គមពេក
- ត្រូវផ្តល់ចំណីឱ្យបានគ្រប់គ្រាន់ហើយមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ ដើម្បីទ្រទ្រង់ការលូតលាស់របស់កូនជ្រូកនៅក្នុងផ្ទៃ។ ជាពិសេសចំណីត្រូវតែសម្បូរជាតិកាល់ស្យូម និងផូស្វ័រព្រោះសារធាតុទាំងពីរនេះមានសារៈសំខាន់ណាស់ក្នុងការលូតលាស់ឆ្អឹងរបស់កូនជ្រូក និងការពារការខ្វះជាតិកាល់ស្យូម និង ផូស្វ័រ ចំពោះមេជ្រូកដែលបណ្តាលឱ្យមេជ្រូកទន់ជើងក្រោយ មុនពេលកើត នៅកំឡុងពេលកើត និងនៅក្រោយពេលកើត ។

<u>ផលលំបាកនៅពេលមេជ្រូកធាត់ពេក:</u> ពិបាកកើត ចិញ្ចឹមកូនមិនបានល្អ អាចដេកសង្កត់កូន មិនសូវសម្បូរទឹកដោះព្រោះខ្លាញ់បានរុំព័ទ្ធកន្សោមដោះ ។

<u>ផលលំបាកនៅពេលមេជ្រូកស្គមពេក:</u> សុខភាពមិនសូវល្អងាយទទួលរងការរាតត្បាតរបស់ជម្ងឺឱកាសនិយមមិនសូវសម្បូរទឹកដោះអោយកូនបៅ មិនងាយរកឈ្មោលនៅក្រោយពេលផ្តាច់ដោះ ។

## ១០- ការថែទាំកូនជ្រូកក្រោយពេលកើត:

**. ការថែទាំកូនដែលកើតមក:** កូនជ្រូកដែលកើតចេញមកមានសភាពសើម ហើយរុំពទ្ធ័ដោយភ្នាសស្ដើង ហើយភ្នាស់ស្ដើងនេះនឹងស្ងួតយ៉ាងឆាប់រហ័ស។ កូនជ្រូកដែលកើតមកហើយអាចស្លាប់ ទៅវិញក្នុងករណីដែលម្ចាស់សត្វមិនបានយកចិត្តទុកដាក់។ ខាងក្រោមនេះគឺជាវិធីសាស្ត្រជួយសត្វក្រោយពេលកើត:

- ត្រូវជូតសម្អាតរំអិលពីច្រមុះ មាត់ និង ខ្លួនកូនជ្រូកឱ្យបានស្អាត
- ត្រូវចាប់សំយ៉ុងក្បាលកូនជ្រូកថ្នមៗដើម្បីរលាក់ទឹករំអិលចេញ
- ផ្លុំបញ្ចូលខ្យល់ចូលតាមរន្ធច្រមុះរបស់កូនជ្រូកយឺតៗ ឬ កាន់ខ្នង និងជើងក្រោយរបស់កូនជ្រូកថ្នមៗ ដោយធ្វើចលនាទៅមុខទៅក្រោយរហូតទាល់តែកូនជ្រូកអាចដកដង្ហើមបាន។

**. ការរក្សាកម្ដៅឱ្យកូនជ្រូក:**

- ត្រូវជូតខ្លួនសត្វជាមួយប្រេងសណ្ដែក
- ត្រូវដាក់កូនជ្រូកដែលទើបនិងកើតក្នុងឡាំង
- ផ្ដល់កម្ដៅកូនជ្រូកដោយប្រើអំពូលភ្លើង (ករណីដែលមានភ្លើងអគ្គីសនី) ឬ ត្រូវដុតធ្យូងក្នុងឆ្នាំងក្អម ដើម្បីកម្ដៅកូនជ្រូក។
- ត្រូវក្រាលកម្រាលទន់ៗនៅបាតឡាំង សម្រាប់ឱ្យកូនជ្រូកដេកដូចជាចំបើងឬស្លឹកចេកងាប់ៗ

**. ការជៀសវាងការដេកកិនកូនជ្រូកទើបកើត:** ដើម្បីជៀសវាងការដេកកិនកូនជ្រូកដែលទើបនិងកើត អ្នកចិញ្ចឹមគួរតែដាក់របារខ័ណ្ឌដើម្បីការពារការដេកកិនកូន។ ការដាក់របារខ័ណ្ឌបែបនេះយ៉ាងហោចណាស់អោយបាន២សប្ដាហ៍ដំបូង។

**. ការដាក់ឱ្យបៅចំពោះកូនជ្រូកទើបកើត:** ក្រោយពេលមេជ្រូកកើតកូនអស់ត្រូវចាប់កូនជ្រូកឱ្យទទួលទឹកដោះដំបូង។ ទឹកដោះដំបូងគឺជាទឹកដោះដែលមានសារធាតុចិញ្ចឹមដែលជួយដល់ការលូតលាស់ដល់កូនជ្រូក និងផ្ដល់ភាពស៊ាំ (អង់ទីគ័រ) ដែលជួយការពារកូនជ្រូកឱ្យជៀសផុតពីជម្ងឺមួយចំនួនមុន និងដល់ពេលកំណត់ថ្ងៃចាក់វ៉ាក់សាំង។ ទឹកដោះ ដំបូងមានរយៈពេលតែ ២-៣ថ្ងៃ ប៉ុណ្ណោះ។ ដើម្បីជៀសវាងកូនជ្រូក ក្លៀប ឬ តូចនៅក្នុងហ្វូង យើងត្រូវឱ្យកូនជ្រូកណាដែលតូចបៅនៅដោះខាងមុខ។

**. ការចាក់ជាតិដែកឱ្យកូនជ្រូក:** ការចាក់ជាតិដែកឱ្យកូនជ្រូកដែលចិញ្ចឹមនៅក្នុងទ្រុងជាការសំខាន់ណាស់ ហើយការចាក់នេះត្រូវចែកជាពីរដំណាក់កាលគឺនៅថ្ងៃទី ៣ នៃអាយុរបស់កូនជ្រូក និងនៅថ្ងៃទី ១០ថ្ងៃ ជាតិដែកដែលត្រូវផ្ដល់ឱ្យ ១ ដងមានកម្រិត ១ សេសេ ហើយចាក់សាច់ដុំ។

**១១- ការវាស់ទម្ងន់របស់ជ្រូក:** ការគណនារកទម្ងន់ជ្រូកតាមរូបមន្តដូចខាងក្រោម




*ទម្ងន់ជ្រូក (គិតជាគីឡូក្រាម)* = $\frac{(\text{ទំហំទ្រូង} \times \text{ទំហំទ្រូង} \times \text{ប្រវែងដងខ្លួន})}{៣៣០} \times ០,៤៥$

**១២- ការការពារ:** កម្មវិធីការពារជំងឺដោយប្រើវ៉ាក់សាំង

វ៉ាក់សាំងរាគសកូនជ្រូក វ៉ាក់សាំងប៉េស្តជ្រូក វ៉ាក់សាំងប៉េស្តជ្រូក

0 ២១ ៣០-៣៥ ៥១-៥៦

អាយុ ២៧ ៤០-៤៥ ៦១-៦២

វ៉ាក់សាំងរាគសកូនជ្រូក វ៉ាក់សាំងសារទឹក វ៉ាក់សាំងសារទឹក

<u>ការថែទាំមេជ្រូកផើម:</u>

ក្រោយពេលដាក់ឈ្មោលបាន ២១ ថ្ងៃ ហើយមេជ្រូកលែងរកឈ្មោលមានន័យថាមេជ្រូកនេះផើមហើយត្រូវអនុវត្តកម្មវិធីដូចខាងក្រោម: កម្មវិធីការពារជំងឺដោយប្រើ<u>វ៉ាក់សាំងជាផលិតផលម៉េឌីវ៉េត:</u>

វ៉ាក់សាំងអ៊ុតក្តាម វ៉ាក់សាំងសារទឹក វ៉ាក់សាំងរាគសកូនជ្រូក

0 ៧៥ ៩៣

អាយុផើម ៦៥ ៧៥ ១០០

វ៉ាក់សាំងរាគសកូនជ្រូក វ៉ាក់សាំងអូហ្សេស្គី វ៉ាក់សាំងសារទឹក

## ១៣- ជម្ងឺដែលជួបប្រទះ

**១៣-១- ជំងឺរាគកូនជ្រូក:** ជំងឺរាគកូនជ្រូកជាជំងឺដ៏ស្មុគស្មាញ និង ខាតបង់យ៉ាងខ្លាំងក្នុងការចិញ្ចឹមជ្រូក ជាពិសេសគឺធ្វើឱ្យការលូតលាស់របស់ជ្រូក មានការយឺតយ៉ាវនៅពេលដែលវាជាសះស្បើយពីជំងឺ។ កូនជ្រូកទើបកើត មុនផ្តាច់ដោះ និង ក្រោយផ្តាច់ដោះច្រើនជួបប្រទះបញ្ហាច្រើនជាងគេនោះគឺជំងឺរាគ។ បុព្វហេតុគឺទៅតាមអាយុកាលរបស់សត្វ។

១- រោគសញ្ញា:

- កូនជ្រូករាគក្រោយពីកើតបាន ១២ ម៉ោង ហើយងាប់នៅ ៤៨ ម៉ោងក្រោយមក។
- ស្គម ស្លេកស្លាំង
- ប្រកាច់ និង ចលនាដូចចែវទូក
- កូនជ្រូកដែលរាគ ឈរនៅតែម្នាក់ឯង
- រាគពណ៌លឿងរាវដូចទឹក (ចំពោះកូនជ្រូកអាយុ ៤ ថ្ងៃ)
- រាគពណ៌ប្រផេះដូចទឹក ពេលខ្លះពណ៌ស (ចំពោះកូនជ្រូកអាយុ ១០-២០ ថ្ងៃ)
- រាគរាវមានពណ៌ប្រផេះ ត្នោត មានក្លិនស្អុយខ្លាំង (ក្រោយពេលផ្តាចដោះហើយ)
- បាត់បង់ជាតិទឹក និងមិនមានការលូតលាស់

២- ការព្យាបាល:

☞ ប្រសិនបើកូនចេះផឹកទឹកត្រូវលាយអេឡិចត្រូលីត

☞ បើកូនជ្រូកចេះស៊ីចំណីត្រូវលាយកូលីធំ: ១០០ក្រាមក្នុងចំណី ២០ គីឡូក្រាមឱ្យស៊ីរយៈពេល ៧ ថ្ងៃ

☞ ឬ ចាក់ហ្វ្លុយមេកុល ( Flumecol) លើកូនជ្រូក: ១ សេសេ សម្រាប់ ទម្ងន់ ៥ គ.ក្រ រយៈពេល ៣ ថ្ងៃ ចាក់សាច់ដុំ ព្រឹក ល្ងាច។

៣- ការការពារ: ដើម្បីកាត់បន្ថយ និង ជៀសវាងការខាតបង់ថវិកាលើការព្យាបាលជម្ងឺរាគកូនជ្រូក។ អ្នកចិញ្ចឹមត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចខាងក្រោម:

- ត្រូវផ្តល់កម្តៅឱ្យកូនជ្រូកទើបកើតឱ្យបានគ្រប់គ្រាន់
- ត្រូវផ្តល់ជាតិដែកឱ្យកូនជ្រូកនៅពេលដែលមានអាយុ ៣ ថ្ងៃ និង ១០ ថ្ងៃ។ ការផ្តល់ជាតិដែកនេះត្រូវផ្តល់ ១ សេសេ ក្នុង ១ ដង។

- ទ្រុងជ្រូកត្រូវតែស្ងួត មានពន្លឺថ្ងៃគ្រប់គ្រាន់ និង មានខ្យល់ចេញចូល

**១៣-២- ជំងឺសារទឹកជ្រូក:** ជំងឺសារទឹកជាជំងឺឆ្លងដែលមានការរាតត្បាតយ៉ាងខ្លាំង និង ធ្វើឱ្យសត្វងាប់យ៉ាងឆាប់រហ័ស ។

១- ភ្នាក់ងារបង្កជំងឺ: បង្កឡើងដោយបាក់តេរីឈ្មោះ ប៉ាស្ទ័រឡេឡាមុលតូស៊ីដា ។

២-ការចម្លងជំងឺ: ការចម្លងនៃជំងឺនេះពីជ្រូកឈឺ ឬ ជ្រូកដែលមានមេរោគនៅក្នុងខ្លួន ហើយចម្លងទៅជ្រូកជា តាមរយៈខ្យល់ដកដង្ហើម ទឹកមាត់ដែលមានមេរោគ ទឹកសំបោរដែលមានមេរោគ ទឹក និង ចំណីដែលមានមេរោគតាមរយៈសម្ភារៈផ្សេងៗទៀត និងតាមរយៈភ្នាក់ងារពេទ្យសត្វភូមិ ដែលបាននាំមេរោគតាមសំ - លៀកបំពាក់ ឬស្បែកជើង។ល។

៣-រោគសញ្ញៈ គេចែករោគសញ្ញានៃជំងឺសារទឹកជា ៣ សណ្ឋានគឺ:

- ☞ ជ្រូកហេវហត់ មិនស៊ីចំណី ចូលចិត្តដេក
- ☞ កម្តៅឡើងក្តៅ ៤១-៤២ អង្សាសេ
- ☞ ពិបាកដកដង្ហើម ហើយមានសំលេងដូចជាមានទឹកនៅក្នុងសួត
- ☞ ឈឺចាប់ត្រង់ច្រមុះ ច្រមុះរៀចហើយងាប់ដោយស្ទះបិទរន្ធច្រមុះ
- ☞ ក្បាលសំយ៉ុងចុះក្រោម ហើយច្រមុះរីកធំឡើងតាមចង្វាក់ដង្ហើម
- ☞ ជ្រូកងាប់ក្នុងរយៈពេលខ្លី
- ☞ រលាកកែវភ្នែក ហៀរទឹកភ្នែក ហៀរទឹកមាត់
- ☞ ជ្រូកកណ្តាស់ ហៀរសំបោរថ្លាៗ ហើយខាប់ៗ
- ☞ រលាកសួតដោយបង្ហាញនូវការក្អកញឹកញាប់
- ☞ ហើមបំពង់ក លៀនអណ្តាតចេញមកក្រៅ
- ☞ ហូរឈាមតាមច្រមុះ
- ☞ មានស្នាមខ្មៅចំនួន ២ នៅក្រោមភ្នែកទាំង ២
- ☞ រលាកសួតក្នុងកម្រិតស្រាល
- ☞ ហើមគន្លាក់ជើង ដើរបាំងខ្ញើចៗ
- ☞ បេះដូងរលាក ហើយមានដកទឹក
- ☞ ហើមសួត និង បំផ្លាញរន្ធច្រមុះ

នៅពេលដែលមានផ្ទុះជំងឺនេះឡើងគេសង្កេតឃើញថា អត្រាកូនជ្រូកងាប់ច្រើន មេធើមរលូតកូន និង ជំងឺនេះរីកសាយភាយយ៉ាងឆាប់រហ័ស។

៤-ការព្យាបាលៈ ការព្យាបាលជំងឺដែលបង្កឡើងដោយបាក់តេរីនៃជំងឺសារទឹកគេអាចប្រើថ្នាំ ១ ក្នុង ចំណោមថ្នាំទាំងអស់ខាងក្រោមនេះ។ ចាក់សាច់ដុំការព្យាបាលមានរយៈពេល ៣-៥ ថ្ងៃ

- ☞ អុកស៊ីតេត្រាសីគ្លីន Oxytetracycline ១ សេសេ សម្រាប់ទម្ងន់ ១០ គ.ក្រ
- ☞ ប៉េនី ឌី អេច អែស Peni DHS ១ សេសេ សម្រាប់ទម្ងន់ ១០ គ.ក្រ
- ☞ ប៊ីយ៉ូឌីល Biodyl ២ សេសេ ក្នុង ១ ក្បាល

៥-ការការពារៈ ដើម្បីជៀសផុតពីជម្ងឺសារទឹកវិធានការសំខាន់គឺត្រូវចាក់វ៉ាក់សាំងឱ្យបានទៀងទាត់។

**១៣-៣- ជំងឺប៉េស្តជ្រូកៈ** ជំងឺប៉េស្តជ្រូកជាជំងឺឆ្លងដ៏កាចសាហាវមួយ ហើយមានការរាតត្បាតយ៉ាងឆាប់ រហ័សបំផុត។ ជំងឺប៉េស្តជ្រូកជាជំងឺមួយ ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចសង្គម ជា ពិសេសជំងឺនេះបាន បង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការខាតបង់ផ្នែកសេដ្ឋកិច្ចរបស់គ្រួសារកសិករ ឬ អ្នកចិញ្ចឹមដែលចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ។

១-ភ្នាក់ងារបង្កជំងឺៈ ជំងឺប៉េស្តជ្រូកជាជំងឺមួយដែលបង្កឡើងដោយវីរុស។

២-ការចម្លងជំងឺៈ ជំងឺប៉េស្តជ្រូកកើតទៅលើជ្រូកគ្រប់វ័យ។ វីរុសនៃជំងឺនេះមានយ៉ាងច្រើន នៅក្នុង បំពងករបស់ជ្រូក ហើយវីរុសទាំងនេះបានបញ្ចេញមកក្រៅតាមរយៈមាត់ (ទឹកមាត់) ច្រមុះ (ទឹកសំបោរ ខ្យល់ដកដង្ហើម) ទឹកភ្នែក ទឹកនោម និង តាមរយៈលាមក។

៣-រោគសញ្ញៈជាទូទៅនៅពេលដែលមាន ការផ្ទុះឡើនៃជំងឺប៉េស្តគេតែងតែសង្កេតឃើញមានជំងឺ មួយចំនួន បានកើតមាននៅពេលដំណាលគ្នានេះដែរដូចជា ជំងឺសារទឹក ជំងឺសាល់ម៉ូណេឡាជាដើម។ ចំពោះ រោគសញ្ញាជំងឺប៉េស្តជ្រូកគឺៈ



- ☞ កម្តៅឡើងក្តៅលើសពី ៤០.៥ អង្សាសេ
- ☞ សត្វដេកគពីលើគ្នា
- ☞ សត្វចុះខ្សោយ ដើរពាន់ជើង ឬ ទន់លោងក្រោយ មិនស៊ីចំណី
- ☞ រលាកកែវភ្នែក ហៀរទឹកភ្នែក ហើយ ភ្នែកឡើងក្រហម (ពពឹកភ្នែក)

☞ លាមកក្មៀន ឬ រាគ

☞ ពិបាកដកដង្ហើម ដង្ហក់

☞ នៅលើភ្នាស់ស្តើងដូចជា លើស្លឹកត្រចៀក ផ្នែកពោះ ភ្លៅមានស្នាមក្រហមអ៊ុច ក្រោយមកវាក៏ប្រែពណ៌ទៅជាក្រហមស្វាយ ឬ ក្រហមក្រម៉ៅ។

☞ ពេលខ្លះគេសង្កេតឃើញសត្វក្អួត

☞ អត្រាស្លាប់របស់ជ្រូកខ្ពស់

- ករណីកើតលើមេធំ: កូនជ្រូកកើតមកងាប់ កូនងាប់ស្វិត មេជ្រូករលូតកូន កូនជ្រូកកើតមកខ្សោយហើមមានសភាពញ័រញាក់

៤- ការព្យាបាល: ជំងឺប៉េស្តមិនមានថ្នាំព្យាបាលទេ ព្រោះថាជំងឺនេះបង្កឡើងដោយវីរុស។

៥-ការការពារ: វិធានការការពារដ៏ប្រសើរបំផុតគឺការចាក់ថ្នាំការពារ ឬ ចាក់វ៉ាក់សាំង។ ការផ្តល់ថ្នាំការពារគួរធ្វើតែចំពោះសត្វដែលមានសុខភាពល្អ។

- ចំពោះកូនជ្រូកដែលកើតពីមេបាដែលមិនបានចាក់ថ្នាំការពារ ឬចាក់ថ្នាំការពារមិនបានទៀងទាត់ត្រូវផ្តល់ថ្នាំការពារដល់កូនជ្រូកនៅពេលដែលវាមានអាយុ ១ សប្តាហ៍។ ត្រូវផ្តល់ថ្នាំការពារម្តងទៀតនៅ ១ ខែ ក្រោយ ពេលចាក់លើដំបូង និង ត្រូវរំលឹករៀងរាល ៦ ខែ ម្តង។

- ចំពោះកូនជ្រូកដែលកើតពីមេបាដែលបានចាក់ថ្នាំការពារបានទៀងទាត់ត្រូវផ្តល់ថ្នាំការពារដល់កូនជ្រូក នៅពេលដែលវាមានអាយុ ៣០-៣៥ថ្ងៃ។ ត្រូវផ្តល់ថ្នាំការពារម្តងទៀត នៅ ២៨ថ្ងៃ ក្រោយពេលចាក់លើដំបូង និងត្រូវរំលឹករៀងរាល់ ៦ខែម្តង។ កម្រិតនៃការចាក់ថ្នាំការពារគឺ ២សេសេ ក្នុង ១ក្បាល ចាក់ជ្រៅទៅក្នុងសាច់ដុំ។

- ចំពោះមេជ្រូកត្រូវផ្តល់ថ្នាំការពារជម្ងឺប៉េស្តឱ្យបានមុនពេលនៃការបង្កាត់។

- ចំពោះជ្រូកបាត្រូវចាក់វ៉ាក់សាំងការពារឱ្យបាន ២ ដង ក្នុង ១ ឆ្នាំ។ កម្រិតនៃការចាក់ថ្នាំការពារគឺ ២ សេសេ ក្នុង ១ ក្បាល ចាក់ជ្រៅទៅក្នុងសាច់ដុំ។

**១៣-៤-ជំងឺអ៊ុតក្តាមជ្រូក:** ជំងឺអ៊ុតក្តាមជាជំងឺឆ្លងរាលដាលយ៉ាងឆាប់រហ័ស ហើយមានសភាពធ្ងន់ធ្ងរ។ ជំងឺនេះកើត ចំពោះសត្វដែលមានប្រចកជើង ចង្វែកដូចជា គោ ក្របី ពពែ ចៀម និង ជ្រូក។ ជំងឺអ៊ុតក្តាមចែកចេញជា ៧ ប្រភេទគឺ ប្រភេទ អូ អា សេ សាត ១-៣ និង អេស្យា ១។

១- មេរោគបង្កជំងឺ: ជំងឺអ៊ុតក្តាមជាជម្ងឺដែលបង្កឡើងដោយវីរុស។

២- កាចម្លងជំងឺ: សត្វដែលមានជំងឺអ៊ុតក្ដាមបានបញ្ចេញមេរោគនេះតាមរយ:ទឹកមាត់ ទឹកដោះគោ លាមក និង ទឹកនោម ។ ការចម្លងជំងឺអ៊ុតក្ដាមនេះតាមរយ:

- តាមរយ:ខ្យល់ដកដង្ហើម
- ការប៉ះពាល់ដោយផ្ទាល់រវាងសត្វឈឺ និង សត្វ ឬ
- តាមរយ:ទឹកមាត់ ទឹកដោះគោ លាមក និង ទឹកនោមដែលមានមេរោគ
- តាមរយ:សម្ភារ:ប្រើប្រាស់ដែលមានមេរោគ
- តាមរយ:សំលៀកបំពាក់ ស្បែកជើងដែលមានមេរោគ

៣-រោគសញ្ញា: ជ្រូកអាចបង្ហាញរោគសញ្ញ ៣-៥ ថ្ងៃ ក្រោយពីមានការប៉ះពាល់ដោយផ្ទាល់ជាមួយ សត្វ ដែលមានជំងឺ:

- ជ្រូកហេវហត់ មិនស៊ីចំណី និង គ្រុនក្ដៅ
- ជើងសត្វមានសភាពឈឺចាប់ និង ស្ពឹកស្រពន់មិនអាចផ្លាស់ទីបាន
- កម្ដៅក្នុងខ្លួនឡើងដល់ ៤១-៤២ អង្សាសេ
- មានពងបែកថ្លានៅលើមាត់ ច្រមុះ ក្រចកជើង កន្សោមដោះ ចុងដោះ ។ ប៉ុន្តែចំពោះជ្រូកគេមិនសូវជួបប្រទះ ពងបែកដែលមាននៅលើអណ្ដាត ។
- មេធើមបណ្ដាលឱ្យរលូត
- កូនកំពុងបៅដោះបណ្ដាលឱ្យងាប់លឿន និង សត្វងាប់ដោយស៊ីចំណីមិនកើត

៤- ការព្យាបាល: ជំងឺអ៊ុតក្ដាមមិនមានថ្នាំព្យាបាលទេប៉ុន្តែគេអាចប្រើអង់ទីប៊ីយ៉ូទីកមួយចំនួនដើម្បីការពារ ការជ្រៀតចូលមេរោគឱកាកនិយមផ្សេងៗទៀត ឬ ដើម្បីព្យាបាលដំបៅ:

- ☞ ប៉េនី ឪ អេច អែស: ១ សេសេ សម្រាប់ទម្ងន់ ១០ គ.ក្រ
- ☞ ប៉ារ៉ាវិន ១000៖ ១ សេសេ សម្រាប់ទម្ងន់ ១០ គ.ក្រ
- ☞ ប៊ីយ៉ូឌីល: ២ សេសេ ក្នុង ១ ក្បាល
- ☞ លាងសម្អាតដំបៅជាមួយទឹកលាងដំបៅ

៥-ការពារជំងឺ: វិធានការល្អបំផុតគឺត្រូវចាក់វ៉ាក់សាំងឱ្យបាន ២ ដង ក្នុង ១ ឆ្នាំ ។

- ចំពោះកូនជ្រូកដែលកើតពីមេ បា ដែលបានចាក់វ៉ាក់សាំង ត្រូវចាក់វ៉ាក់សាំងនៅអាយុ ៦0ថ្ងៃ និង ចាក់លើកទី ២ នៅ ២៨ ថ្ងៃក្រោយពីការចាក់លើកទី ១ ។

- ចំពោះកូនជ្រូកដែលកើតពីមេបាដែលមិនបានចាក់វ៉ាក់សាំង ត្រូវចាក់វ៉ាក់សាំងនេះនៅអាយុ ១៥ ថ្ងៃ និង ចាក់លើកទី ២ នៅ ២៨ ថ្ងៃ ក្រោយពីចាក់លើកទី ១។

- ត្រូវរំលឹករៀងរាល់ ៦ ខែ ម្តង។

**១៣-៥-ជំងឺដែលបង្កឡើងដោយពពួកប៉ារ៉ាស៊ីតៈ** ប៉ារ៉ាស៊ីតជាសត្វល្អិតតូចៗដែលរស់នៅខាងក្នុងខ្លួនសត្វ នៅលើខន្លួសត្វ (គោ ក្របី ជ្រូក មាន់ ទា)។ ប៉ារ៉ាស៊ីតខ្លះអាច មើលឃើញនឹងភ្នែក និង ខ្លះទៀតមិនអាចមើលឃើញដោយភ្នែក។ នៅពេលប៉ារ៉ាស៊ីតចូលទៅក្នុងខ្លួនសត្វ វាលូតលាស់ ទៅជាពេញវ័យ ហើយបង្កើតជាពង។ ពងនេះចេញពីក្នុងខ្លួនសត្វមកក្រៅ (ភាគច្រើនតាមរយៈលាមក)។ ពងនេះអាច ចម្លងទៅ សត្វផ្សេងៗទៀត ហើយវាលូតលាស់ទៅជាពេញវ័យរួចហើយបង្កើតពងសារជាថ្មី។ ប៉ារ៉ាស៊ីតមានពីរប្រភេទគឺ ប៉ារ៉ាស៊ីតខាងក្នុង និង ប៉ារ៉ាស៊ីតខាងក្រៅ

១- ប៉ារាស៊ីតខាងក្នុងៈ ភាគច្រើននៃប៉ារ៉ាស៊ីតខាងក្នុងគឺជាពពួកព្រូនដែលជាព្រូនមូល សំប៉ែត អៀន តេញ៉ា ។ល។ ប៉ារ៉ាស៊ីតខាងក្នុងរស់នៅកន្លែង ខុសៗគ្នាដូចជា នៅក្នុង ក្រពះ ពោះវៀន ថ្លើម សួត សាច់ដុំ ។ល។ ចំណីអាហារ ដែលសត្វស៊ីដើម្បីយកទៅចិញ្ចឹមសរីរាង្គ កាយ មួយភាគធំនៃចំណីអាហារត្រូវបានស្រូបយកដោយពួកប៉ារ៉ាស៊ីត ដែល ធ្វើឱ្យសត្វចុះស្គម ការលូតលាស់យឺត រោមស្រ អាប់ហើយបាស់ៗ សត្វមាន សភាពស្លេកស្លាំងដែលជាហេតុនាំឱ្យសត្វ ងាយទទួលរងជម្ងឺផ្សេងៗ។ ក្នុងករណីដែលព្រូនមាន ចំនួនច្រើនអាចបណ្តាលឱ្យសត្វស្លាប់បាន។

២-ប៉ារ៉ាស៊ីតខាងក្រៅៈ ពពួកប៉ារ៉ាស៊ីតខាងក្រៅ រស់នៅលើស្បែកសត្វ ឬ ក្រោមស្បែកសត្វ។ វាធ្វើឱ្យសត្វរមាស់ នៅមិនស្ងៀម អេះច្រើន ចុះស្គម ជួនកាលវាធ្វើឱ្យស្បែកឡើងក្រម៉ះ។ ប៉ារ៉ាស៊ីតខ្លះទៀត ដូចជា ចៃ ឬ ដង្កែ ខាំជញ្ជក់ឈាមពីសត្វ ដែលធ្វើឱ្យសត្វអេះកើត ទៅជារមាស់។

៣-រោគសញ្ញាៈ សត្វដែលកើតជម្ងឺដែលបង្កឡើងដោយប៉ារ៉ាស៊ីតបង្ហាញរោគសញ្ញាដូចខាងក្រោមៈ សត្វចុះស្គម ការលូតលាស់យឺត ស្បែកជ្រីវជ្រួញ រោមស្រអាប់ មានដំបៅរមាស់ សត្វរាគ មានសភាពស្លេកស្លាំង

៤- ការព្យាបាលៈអ៊ីវ៉ូមិចស៊ីបភើៈ ១ សេសេ សម្រាប់ទម្ងន់ ៣៣ គ.ក្រ គឺចាក់សើស្បែក។

□